៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ :២៩៧

ចុះថ្ងៃទី ២៩-៥-០៩

សាលដីកា

លេខ :៥៨ ក្រ/ព

ចុះថ្ងៃទី ០៦-៦-១២

តាមនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើតាម ក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទីសាលាឧទ្ធរណ៍ នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ ដោយមានសមាសភាពចូលរួមដូចតទៅ :

សមាសក្រុមប្រឹក្សាជំនុំជំរះ

១. លោក [redacted] ជាប្រធាន

២ លោក [redacted] ជាចៅក្រមប្រឹក្សា

៣. លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជីសវនាការ

អ្នកស្រី [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌលេខ :២៩៧ ចុះថ្ងៃទី ២៩ ខែ ៥ ឆ្នាំ ២០០៩

ដែលមាន :

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ ២១ឆ្នាំ កើត និង ទីលំនៅភូមិ ទួលតាឯក ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង សាសនាព្រះពុទ្ធ របរកសិ កម្មករសំណង់ ឪពុកឈ្មោះ [redacted] នៅរស់ ទោសពីមុនគ្មាន កំរិតវប្បធម៌ ថ្នាក់ទី៤ថ្មី ។ ឃុំខ្លួនថ្ងៃទី ១១-០២-២០០៨ ។ (ស) ម្តាយឈ្មោះ [redacted]

- មានលោក [redacted]មេធាវីការពារ

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ ២៥ឆ្នាំ កើតនៅភូមិ ទួលតាឯក ឃុំ ស្វាយប៉ោ១ ស្រុកទីរួមខេត្ត បាត់ដំបង មានទីលំនៅបច្ចុប្បន្នភូមិ អូរតាកាំ២ ឃុំ ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង សាសនាព្រះពុទ្ធ របរកសិ កម្មករ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] (រ) នៅរស់ ។ (ក្រៅឃុំ)

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ ៣១ឆ្នាំ កើតនៅភូមិ ទួលតាឯក ឃុំ ស្វាយប៉ោ១ ស្រុកទីរួមខេត្ត បាត់ដំបង មានទីលំនៅបច្ចុប្បន្នភូមិ អូរតាកាំ ២ ឃុំ ទួលតាឯក ស្រុក-ខេត្ត បាត់ដំបង សាសនាព្រះពុទ្ធ របរកសិ កម្មករ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅរស់ ។ (ក្រៅឃុំ)



Scanned by CamScanner

ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ អាយុ ១៨ឆ្នាំ កើតនៅភូមិ កំពង់ក្របី ឃុំ ឯកភាព ទីរួមខេត្ត បាត់ដំបង មានទីលំនៅបច្ចុប្បន្នភូមិ ទួលតាឯក ឃុំ ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង សាសនាព្រះពុទ្ធ របររកស៊ី មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted]ស់ (ក្រៅឃុំ)

**ត្រូវចោទពីបទ** :មនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ទួលតាឯក ឃុំ ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ។

*បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។*

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ ព្រៃទទឹង ឃុំ ជ្រៃ ស្រុក ថ្មគោល ខេត្ត បាត់ដំបង ។

តាមសេចក្តីសុំប្តឹងទាស់លេខ :៧២ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់ឈ្មោះ [redacted] ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ :៣៨ (៣) ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសាលដីកាទាំងមូល ។

***ឯរឿងហេតុមានដូចតទៅ :***

កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៨ វេលាម៉ោង ១១យប់ ជនល្មើសឈ្មោះ [redacted] ភេទប្រុស ដែលមានទីលំនៅភូមិ ទួលតាឯក ឃុំ ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង និង បក្ខពួក បាននាំគ្នាពួនស្ទាក់ចាំកាក់ម៉ូតូរបស់ជនរងគ្រោះ ពេលឃើញម៉ូតូរបស់ជនរងគ្រោះជិះកាត់រំបតាមផ្លូវរថភ្លើងមកខាងត្បូងបានចម្ងាយប្រហែលជា ១០០ម ជនល្មើសរូបនេះបានចេញមកកាក់ពីមុខម៉ូតូហើយបញ្ជាឱ្យឈប់ បន្ទាប់មកទៀតបក្សពួករបស់ជនល្មើសបានលូកហោប៉ៅ របស់ជនរងគ្រោះ [redacted]កប្រាក់អស់ចំនួន ១០.០០០រៀល ចំណែកជនរងគ្រោះ [redacted] រត់ចេញពីម៉ូតូចម្ងាយប្រហែលប្រាំម៉ែត្រ តែត្រូវជនល្មើសស្ទាក់ជាប់ ហើយទាមទារយកទូរស័ព្ទដៃ ដោយជនរងគ្រោះមិនព្រមឱ្យជនល្មើសក៏កាប់ និង ចាក់ទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់នៅនឹងកន្លែងតែម្តង បន្ទាប់ពីធ្វើសកម្មភាពទៅលើជនរងគ្រោះហើយ ជនល្មើសក៏នាំគ្នារត់គេចខ្លួនអស់ទៅ ។

តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ [redacted]ង់ពីមនុស្សឃាដដោយចេតនា ដោយសំអាងហេតុថា កាលពីថ្ងៃទី ០៧-កុម្ភៈ-២០០៨ ម៉ោង០១ និង ០០នាទី ខ្លួនបានទទួលដំណឹងពីឈ្មោះ [redacted] ប្រុស ប្រាប់ថា ឈ្មោះ [redacted] ត្រូវរបួសធ្ងន់ប្រហែលស្លាប់ហើយ និង [redacted] ភេទប្រុស អាយុ ២៧ឆ្នាំ ត្រូវរបួសនៅត្រង់ចំណុចស្ថានីយ៍រថភ្លើងខេត្ត បាត់ដំបង ។ ពេលនោះខ្លួនមកដល់កន្លែងកើតហេតុនៅវេលាម៉ោង ២ និង ៣០នាទី ឃើញឈ្មោះ [redacted] ស្លាប់នៅខាងជើងផ្លូវរថភ្លើងហើយបាត់ទូរស័ព្ទដៃម៉ាកសាំសុនលេខ : ០១២ ១៩៤៦១០៥ និង ប្រាក់មួយចំនួន ។ សំណូមពរសុំឱ្យសមត្ថកិច្ចជួយស្រាវជ្រាវរកសំភារះឱ្យខ្លួនវិញ ចំណែកជនល្មើសសុំឱ្យសមត្ថកិច្ចផ្តន្ទាទោសទៅតាមច្បាប់ ។

Scanned by CamScanner

បានឃើញចម្លើយរបស់ឈ្មោះ [redacted] ជាជនជាប់ចោទឆ្លើយក្នុងសាលក្រមថា ខ្លួនមិនបានសម្លាប់គេទេ ហើយមិនបានដឹងថា គេស្លាប់ដោយ លុះព្រឹកឡើងទើបដឹង នៅថ្ងៃនោះម៉ោង ៤ ខ្លួននៅផ្ទះ លុះម៉ោង ៥ ខ្លួនបានទៅលេងបាល់ទះមុខទឹក ហើយទៅមើលគេលេងល្បែង ឈ្មោះ [redacted] បានមកលេងផ្ទះខ្លួន ហើយខ្លួនក៏បបួលវាទៅមើលជើង រួចទៅជិះលេងនៅក្រោមដើមទឹកដោះគោម៉ោង ១០ជាងទើបមកវិញ ខ្លួនមិនបានដឹងថា [redacted] ស្លាប់នៅពេលណាទេ លុះព្រឹកឡើងទើបដឹង មិនដឹងអ្នកណាសម្លាប់គេទេ តែនៅយប់នោះវេលាម៉ោង ១២ [redacted] មករកខ្លួនរួចប្រាប់ខ្លួនថា វាកាប់គេ ខ្លួនក៏បានស្តីឱ្យវាហើយវាក៏ចេញបាត់ទៅ . ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] ទៅផ្ទះរបស់ខ្លួនតែម្នាក់ឯងនៅម៉ោង១២យប់នោះពុំមានកាំបិតទេ . [redacted] ព្រោះនៅភូមិជាមួយ តែយប់នោះខ្លួនមិនបានជួបទេ ខ្លួនមិនដែលមានដាវសាមូរ៉ៃទេ ។ ខ្លួនបានឈរលេងនៅក្រោមដើមទឹកដោះគោចាប់ពីម៉ោង ៨យប់រហូតដល់ម៉ោង ១០យប់ ដោយមានគ្នាបីនាក់មានឈ្មោះ [redacted] សំណូមពរលើកលែងចោទប្រកាន់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ : ២៣ "យ" ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់សាលាដំបូងខេត្ត បាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១. ផ្តន្ទាទោស :

ក- ឈ្មោះ [redacted] ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំគត់) តម្រូវឱ្យធ្វើការគិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។

ខ- ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ

គ- ឈ្មោះ [redacted] ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ

ឃ- ឈ្មោះ [redacted] ហៅ ហុង ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ

តម្រូវឱ្យធ្វើការក្នុងម្នាក់ ១ កំណត់១៥ឆ្នាំ (ដប់ប្រាំឆ្នាំគត់) គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទ : មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិ ទួលតាឯក ឃុំ ទួលតាឯក ស្រុក បាត់ដំបង ខេត្ត បាត់ដំបង កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំពោះមុខឈ [redacted] ចំពោះមុខដើមបណ្តឹង ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់

បានឃើញសេចក្តីប្រកាសប្តឹងឧទ្ធរណ៍លេខ :៤១ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ពីសាលក្រមរបស់សាលាដំបូងខេត្ត បាត់ដំបង ប្រឆាំងសេចក្តីសំរេចខាងលើ ។

បានឃើញរបាយការណ៍រឿងចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៥ របស់សាលាឧទ្ធរណ៍

Scanned by CamScanner

បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី ០៤ ខែ ០១ ឆ្នាំ ២០១០ របស់មហាអយ្យការសាលាឧទ្ធរណ៍

បានឃើញដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជំរះលេខ :០៩/១២ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២ របស់សាលាឧទ្ធរណ៍ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ :៣៤ ញ ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣ ខែ ៣ ឆ្នាំ ២០០៩ របស់ឈ្មោ[redacted]ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផុតកំណត់ច្បាប់ ។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ :២៣ (ឃ) ចុះថ្ងៃទី ២៣ ខែ ០២ ឆ្នាំ ២០០៩ របស់សាលាដំបូងខេត្ត បាត់ដំបង ទុកជាបានការដដែល ។

៣. បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោ[redacted]

៤. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៣-៨-២០១០ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹង ។ ទុកសិទ្ធិឲ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿង

ឈ្មោះ[redacted]ឆ្លើយថា មុនកើតហេតុឈ្មោះ យូ ឧត្តម បបួលខ្លួនទៅបក់ជើងដំ នៅទីនោះជាទីវាយមួយអ្នកណាក៏ទៅបក់នៅទីនោះ ហើយបបួលខ្លួនទៅមើលគេលេងចុងចាស់ លុះដើរចេញមកជួបឈ្មោ[redacted]ឈ្មោះ [redacted] ហើយបានសួរសុខទុក្ខគ្នាជាធម្មតា រួចឈ្មោ[redacted]បបួលខ្លួនទៅ ហើយមកឈ្មោះ [redacted] [redacted]ស្លាប់បានដើរទៅកន្លែងចុងចាស់ បន្ទាប់មកខ្លួនបានទៅផ្ទះដេកវិញ ក្រោយមកឈ្មោ[redacted]នទៅគោះទ្វារ សួររកប្រាំឈ្មោ[redacted]ទៅមីងផ្ទះខ្លួនហើយ និយាយថា រកឃើញកាប់[redacted]ផ្លូវទ្វេរបានដេញវាឲ្យចេញ បន្ទាប់ខ្លួនបានដេកលក់ទៅ លុះព្រឹកឡើង គេហៅខ្លួនទៅប៉ុស្តិ៍មកក្រុងត្រូវគេចាប់ខ្លួនតែម្តង ។ ខ្លួនមិនបានប្រព្រឹត្តទេ មុនកើតហេតុមិនបានជួបឈ[redacted]មកផ្ទះនៅម៉ោង ១០ ទៅ ១០:៣០នាទី មានឈ្មោ[redacted] មួយ ដែលខ្លួនអង្គុយជិតនិយាយគ្នាបណ្តើរ ។ នៅសាលាដំបូងខ្លួនមានបងថ្លៃឈ្មោ[redacted] ។ ជនរងគ្រោះខ្លួនស្គាល់មុខ តែមិនស្គាល់ឈ្មោះទេ [redacted] [illegible] មិនស្គាល់ទេ គាត់ប្តឹងថាខ្លួនកាន់ដៃវែងម៉ូតូ [redacted]ជនរងគ្រោះធ្លាប់ឃើញ ។ ខ្លួននៅបាត់ដំបងជាងប្រាំឆ្នាំ មិនដែលស្គាល់សាក្សីនេះទេ ។ សព្វថ្ងៃជនដែលចាប់បាន គឺឈ្មោ[redacted] ខ្លួនបានឃើញនៅក្នុងអាគារផ្លាស់តែម្តង ជាប់នៅខេត្ត បាត់ដំបង មិនដឹងថាវាធ្វើយ៉ាងណាទេ ។ សំណូមពរសុំមេត្តាលើកលែងការចោទប្រកាន់ព្រោះខ្ញុំមិនបានប្រព្រឹត្ត ដូចការចោទប្រកាន់ ។

**តំណាងមហាអយ្យការសន្និដ្ឋានថា** ពាក់ព័ន្ធនឹងរឿងនេះមានភស្តុតាងច្រើន ចំពោះជនជាប់ចោទ ប៉ុន្តែពុំមានចម្លើយ សូមឲ្យក្រុមប្រឹក្សាលើកទៅថ្ងៃក្រោយដើម្បីកោះហៅសាក្សីមើលក្នុងឲ្យឃើញពិតសាក្សីទាំងអស់ទទួលយកបាន

Scanned by CamScanner

ឈ្មោះ [redacted] សាកសួរនាពេលសវនាការពេលក្រោយ សូមឱ្យក្រុមប្រឹក្សាពិនិត្យពិចារណា និង សម្រេចតាមច្បាប់ ។

លោកមេធាវី [redacted] ទ្ធិដ្ឋានការពារថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសសម្លាប់មនុស្សទេ សូមក្រុមប្រឹក្សាបង្អង់លើកទៅថ្ងៃក្រោយដើម្បីរកការពិត កុំឱ្យកូនក្តីខ្លួនជាប់ដោយអយុត្តិធម៌ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឆ្លើយ និង ស្នើសុំ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ពិនិត្យឯកសារដែលពាក់ពន្ធ័ក្នុងសំណុំរឿង

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## សាលាឧទ្ធរណ៍-យល់ឃើញថា

១- បណ្តឹងទាស់ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោ [redacted] ងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ :៣៨ (៣) ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- នៅពេលសវនាការសាលាឧទ្ធរណ៍ ដើមបណ្តឹងទាស់មិនបានយកភស្តុតាងថ្មីមកសាលាឧទ្ធរណ៍ ដើម្បីឱ្យសាលាឧទ្ធរណ៍ ធ្វើការកែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើយ ។

៣- តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា មានភាពស្មុគ្រស្មាញច្រើន ហើយចំណុចជនជាប់ចោទលើកឡើងយើងទទួលយកបាន ប៉ុន្តែសាក្សីគាត់មិនមានចម្លើយ ហើយមេធាវីគាត់មិនស្វែងរកមកដាក់ជូនតុលាការកន្លងមក ជាក់ស្តែងឈ្មោ [redacted] បចំណុចនេះមេធាវីមិនរកឱ្យដើម្បីដោះបន្ទុកឱ្យជនជាប់ចោទរូបនេះ ហើយសូមក្រុមប្រឹក្សាលើករឿងនេះទៅថ្ងៃក្រោយដើម្បីកោះហៅឈ្មោះ [redacted] សាកសួរនាពេលសវនាការពេលក្រោយ ។ សាលាឧទ្ធរណ៍បានទុកពេលច្រើនមកហើយ គប្បីមិនលើករឿងនេះតទៅទៀតទេ ។

៤- រឿងក្តីនេះត្រូវបានសាលាឧទ្ធរណ៍ជំនុំជំរះម្តងរួចមកហើយកាលពីថ្ងៃទី ១៣-៩-២០១០ តាមអំណាចសាលដីកាលេខ :៣៨ (៣) ហើយរហូតមកទល់ពេលនេះពុំមានភស្តុតាងណាបញ្ជាក់ថា នៅថ្ងៃកើតហេតុជនជាប់ចោទពិតជាមិននៅកន្លែងកើតហេតុ និង មិនបានប្រព្រឹត្តបទល្មើសមនុស្សឃាដដូចការអះអាងរបស់ជនជាប់ចោទឡើយ ។

៥- សាលដីកាព្រហ្មទណ្ឌលេខ :៣៨ (៣) ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង គតិច្បាប់ហើយ គប្បីតម្កល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងទាស់ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោ [redacted] ាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

Scanned by CamScanner

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ :៣៨ (ញ) ចុះថ្ងៃទី ១៣ ខែ ៨ ឆ្នាំ ២០១០ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ

- បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]

Scanned by CamScanner